INTERNATIONAL MONETARY FUND
EXTERNAL RELATIONS DEPARTMENT

ការផ្សាយព័ត៌មាន
សំរាប់ការចែកផ្សាយជាប្រញាប់
០១ សីហា ឆ្នាំ ២០០៧

មូលនិធិរូបិយវត្ថុអន្តរជាតិ
Washington, D.C. 20431 USA

# សេចក្តីថ្លែងការដោយនាយកគ្រប់គ្រង រ៉ូឌ្រីហ្គូ ដឺរ៉ាតូ នៃមូលនិធិរូបិយវត្ថុអន្តរជាតិ អំពីការធ្វើទស្សនកិច្ច របស់គាត់មកកម្ពុជា

លោក រ៉ូឌ្រីហ្គូ ដឺរ៉ាតូ នាយកគ្រប់គ្រងនៃមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានចេញសេចក្តីថ្លែងការដូចតទៅ នៅភ្នំពេញ ក្នុងថ្ងៃនេះ :

"ខ្ញុំសប្បាយរីករាយ ដែលជានាយកគ្រប់គ្រងទី ១ របស់មូលនិធិរូបិយវត្ថុ មកធ្វើការទស្សនកិច្ចមកកម្ពុជា តាំងពីឆ្នាំ ១៩៩៣ មក ។ ថ្ងៃនេះខ្ញុំមានឯកសិទ្ធិនៃការជួបជាមួយ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី និង សម្តេច ហេង សំរិន ប្រធានរដ្ឋសភា ។ ខ្ញុំបានជួបផងដែរ ឯកឧត្តម គាត ឈន់ ទេសរដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឯកឧត្តម ជា ចាន់តូ ទេសាភិបាល នៃធនាគារជាតិនៃកម្ពុជា រួមទាំង ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រីនៃក្រសួងពាណិជ្ជកម្ម ក៏ដូចជារដ្ឋមន្ត្រី និង មន្ត្រីជាន់ខ្ពស់នានានៅក្នុងក្រុមសេដ្ឋកិច្ចរបស់រដ្ឋាភិបាល ។

"ខ្ញុំស្ងើចសរសើរចំពោះកំណើនដ៏លឿនរបស់សេដ្ឋកិច្ចកម្ពុជា និង ចំពោះវិធានការណ៍ម៉ាក្រូសេដ្ឋកិច្ចដ៏ប្រុងប្រយ័ត្ន ជាទូទៅ ក្នុងការអនុវត្តន៍គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ។ គោលនយោបាយសារពើពន្ធ និង រូបិយវត្ថុដ៏សមស្រប លើកស្ទួយការជឿទុកចិត្ត និង បង្កើនសកម្មភាពនៃវិស័យឯកជន ហើយនិន្នាការទាំងនេះនៅតែបន្តក្នុងឆ្នាំ ២០០៧ ។ យើងសង្ឃឹមថា សេដ្ឋកិច្ចនឹងមានកំណើនប្រហែល ៩ភាគរយ ក្នុងឆ្នាំនេះ ជាមួយនិងអតិផរណា ដែលស្ថិតនៅទាប ។

Washington, D.C. 20431 • Telephone 202-623-7100 • Fax 202-623-6772 • www.imf.org

"ក្នុងជំនួបរបស់ខ្ញុំជាមួយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ខ្ញុំបានបញ្ជាក់ថា ការអនុវត្តន៍ម៉ាក្រូសេដ្ឋកិច្ចដ៏ល្អនេះប្រកបដោយចិរភាព ផ្តល់នូវមូលដ្ឋានដ៏រឹងមាំមួយសំរាប់ការកែលំអកំរិតជីវភាព និង កាត់បន្ថយភាពក្រីក្រក្នុងកំរិតខ្ពស់ជាងទៀត។ គឺមានសារសំខាន់ក្នុងរយៈពេលខាងមុខ ដើម្បីធ្វើអោយមានភាពជឿនលឿនជាបន្ថែមទៀត ក្នុងការពិនិត្យដោះស្រាយភាពប្រឈមជាគន្លឹះនានា ដើម្បីអោយការអភិវឌ្ឍន៍មានចិរភាព និង ធានាថាផលប្រយោជន៍នឹងត្រូវបានចែករំលែកដោយមិនលំអៀង។ ខ្ញុំបានរីករាយដោយដឹងថាមានកំណើនយ៉ាងខ្លាំងនៃចំណូលរបស់រដ្ឋាភិបាលក្នុងឆ្នាំនេះ ។ ខ្ញុំបានលើកទឹកចិត្តរដ្ឋាភិបាលអោយបន្តការខំប្រឹងប្រែងរបស់ខ្លួនដើម្បីកែលំអរដ្ឋបាលចំណូល និង ពង្រីកមូលដ្ឋានពន្ធក្នុងថវិកាឆ្នាំ ២០០៨ ហើយប្រើប្រាស់ចំណូលដែលបានមកដើម្បីបង្កើនចំណាយដែលត្រូវការយ៉ាងខ្លាំង សំរាប់គំរោងហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាពខ្ពស់ កំណែទំរង់ប្រាក់បៀវត្សជាយុទ្ធសាស្ត្រនៃវិស័យសាធារណៈ និង សំរាប់វិស័យអាទិភាពនានាដូចជា សុខាភិបាល និង អប់រំ ។

"ការរកឃើញប្រេងគឺជាដំណឹងវិជ្ជមានសំរាប់ប្រទេសកម្ពុជា ហើយខ្ញុំបានយល់ស្រមជាមួយរដ្ឋអំណាចកម្ពុជាដែលថា ធានាអោយមានផលប្រយោជន៍ពេញលេញអំពីប្រេងបំរុងគឺជាភាពប្រឈមដ៏គន្លឹះមួយ។ ខ្ញុំបានស្វាគមន៍ចំពោះការខំប្រឹងប្រែងដែលកំពុងមាននៅក្នុងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីកសាងរបបសារពើពន្ធដែលសមស្របសំរាប់វិស័យប្រេង។ ហើយខ្ញុំបានគាំទ្រដល់ការសំរេចចិត្តរបស់សម្តេចនាយករដ្ឋមន្ត្រីដើម្បីធ្វើវិសោធនកម្មច្បាប់ពន្ធដារជាមួយនិងប្រកាសនានាសំរាប់ការយកពន្ធលើវិស័យប្រេង ហើយបានគូសបញ្ជាក់ពីសារសំខាន់នៃតម្លាភាពក្នុងការគ្រប់គ្រងចំណូលពីប្រេង ។

"ទូលំទូលាយជាងនេះ ការកែលំអអភិបាលកិច្ចជាបន្តគឺមានសារៈសំខាន់ មិនគ្រាន់តែសំរាប់ធ្វើអោយប្រសើរនូវបរិស្ថានវិនិយោគនៅកម្ពុជាប៉ុណ្ណោះទេ តែថែមទាំងពង្រឹងចំណងទាក់ទងរវាងកំណើន និង ការកាត់បន្ថយភាពក្រីក្រ ។ ខ្ញុំបានស្វាគមន៍ចំពោះការរីកចំរើនដែលកំពុងតែមានក្នុងការកែទំរង់ប្រព័ន្ធនានានៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ការអនុវត្តន៍អោយបានជោគជ័យនៃកម្មវិធីនេះនឹងរួមចំណែកពង្រឹងអភិបាលកិច្ចក្នុងការប្រើប្រាស់ធនធានសាធារណៈនៅក្នុងរយៈពេលវែង ។

"វិស័យធនាគារកំពុងតែរីកដុះដាលយ៉ាងលឿន។ កំណើនវិស័យហិរញ្ញវត្ថុមានសារៈសំខាន់ណាស់ចំពោះការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ដូច្នេះហើយបានជាការពិភាក្សានានារបស់ខ្ញុំជាមួយឯកឧត្តមទេសាភិបាល ជា ចាន់តូ បានផ្តោតទៅលើប្រព័ន្ធធនាគារ។ យើងមានទស្សនៈស្របគ្នាទាំងស្រុងថា ការត្រួតពិនិត្យដ៏ខ្លាំងគឺមានសារៈសំខាន់ណាស់ដើម្បីការពារភាពរឹងមាំនៃប្រព័ន្ធធនាគារ ហើយខ្ញុំរីករាយដោយដឹងថាការខំប្រឹងប្រែងនានាដើម្បីបង្កើតអោយមានការគោរពយ៉ាងតឹងរឹងនូវបរិស្ថានបទបញ្ញត្តិ នឹងត្រូវបានពង្រឹង ។

"នៅចុងបំផុត ខ្ញុំបានមានឱកាសទទួលទានអាហារពេលព្រឹក នៅពេលព្រឹកនេះជាមួយក្រុមយុវជនស្ម័គ្រចិត្តកម្ពុជា (Youth Star Cambodia) នៅទីនោះខ្ញុំបានស្តាប់អ្នកស្ម័គ្រចិត្តកម្ពុជាពិពណ៌នាអំពីបទពិសោធន៍ និងទស្សនៈនានារបស់ខ្លួនអំពីការអភិវឌ្ឍន៍នៅឯកំរិតសហគម។

"ក្នុងការពិភាក្សាទាំងអស់របស់ខ្ញុំ ខ្ញុំបានប្រទះឃើញនូវការវិនិច្ឆ័យដ៏រឹងមាំនិងគួរអោយលើកទឹកចិត្តមួយអំពីសុទិដ្ឋិនិយមសំរាប់អនាគតរបស់កម្ពុជា។ ខ្ញុំជឿជាក់ថាសុទិដ្ឋិនិយមនេះត្រូវបានកំនត់ច្បាស់ ហើយជាមួយនិងការអនុវត្តន៍គោលនយោបាយដ៏ល្អ កំណើនសេដ្ឋកិច្ចដ៏ខ្លាំងក្លានឹងបន្ត ។"